# ពីសិលាចារឹកទៅជាយ័ន្ត

កាលឆ្នាំ២០១៣ ខ្ញុំបានទទួលរូបភាពសិលាចារឹកមួយនេះពីលោក **រ៉ុំ សិរីរិបុល**។ លោកទទួលបានរូបនេះពីបងស្រីជីដូនមួយរបស់លោកឈ្មោះ **កង ស្រីនាង** ជាអ្នកប្រកបអាជីវកម្មថតចម្លងឯកសារនៅឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល។ កាលនោះមានបុរសចំណាស់ម្នាក់ យករូបនេះមកថតចម្លងនិងអ៊ុតផ្លាស្ទិករឹង ធ្វើជាយ័ន្តសម្រាប់ដាក់តាមខ្លួនឱ្យបានសេចក្ដីសុខសប្បាយ និងរកស៊ីមានបាន។

អត្ថបទចារឹកនេះមានអក្សរចំនួន៥បន្ទាត់ និងអាចកំណត់បានយ៉ាងច្បាស់ថាជាអក្សរនិងភាសាខ្មែរសម័យមុនអង្គរ។ ផ្អែកលើលក្ខណៈតួអក្សរ យើងអាចប៉ាន់ប្រមាណថាសិលាចារឹកនេះចារនៅចន្លោះចុងស.វ.ទី៧និងស.វ.៨គ.ស.។ ថ្មដែលជ្រើសរើសមកចារទំនងជាប្រភេទថ្មថ្ងើមអណ្ដើក ឬថ្មស្រទាប់ ដែលយើងតែងប្រទះឃើញជាទូទៅនៅសម័យមុនអង្គរ ជាពិសេស គឺនៅតំបន់ភាគត្បូងប្រទេស ក្នុងខេត្តកណ្ដាល តាកែវ កំពង់ស្ពឺ និងកំពត។ រូបរាងថ្មនេះគួរតែជាសន្ទឹកសីមាដែលមានទម្រង់តាមធម្មជាតិ ពុំបានរចនារូបរាងនោះឡើយ។ ផ្នែកខាងលើអត្ថបទមានឆ្លាក់រូបចក្រមួយដែលផ្នែកខាងក្រៅរង្វង់ មានសញ្ញារាងត្រីកោណឬផ្ទៃចក្រ មានសណ្ឋានប្រហាក់ប្រហែលនឹងត្របកផ្កាឈូកចំនួន២៦។ បន្ទាប់មកមានខ្សែវណ្ឌពីរ ឯផ្ទៃខាងក្នុងឆ្លាក់កាំចក្រចំនួន៨ ចំផ្នែកណ្ដាលចក្រមានឆ្លាក់រង្វង់តូចដែលមានដុំមូលនៅខាងក្រៅចំនួន៨ ព័ទ្ធជុំវិញខ្សែវណ្ឌមួយខ្សែ។ យើងបានប្រទះឃើញសិលាចារឹកដែលមានសញ្ញាចក្រនៅខាងលើដូចគ្នានេះដែរ គឺសិលាចារឹកមកពីស្នាយពល K.៦៦២ និងមួយទៀតជាសិលាចារឹកមកពីអង្គរបុរី K.១២១៦ ដែលមានរូបចក្រ សង្ខ ត្រីសូល និងវជ្រ។ នៅខាងក្រោមរូបចក្រ មានរចនាជាខ្សែបន្ទាត់ផ្ដេកមានក្បាច់ពងត្រីចំនួន៤៤។ ការរចនាខ្សែបន្ទាត់ជាក្បាច់ពងត្រីបែបនេះ យើងប្រទះឃើញច្រើនណាស់នៅសម័យមុនអង្គរដូចជា៖K.៧៩, K.៣៦៧, K.៦៨៩, K.៧៨៤, K.៧៩០, K.៩៤០, K.១១៥០ និង ក.២៧១៨ ជាដើម។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## ពីសិលាចារឹកទៅជាយ័ន្ត

អត្ថន័យសិលាចារឹកខ្វីនេះ និយាយអំពីដង្វាយរបស់ អាចារ្យធម្មបាល (អាចាយ៌្យធម៌្មបាល) ថ្វាយចំពោះទេពព្រះនាមស្រីមហាបុរុសោត្តមស្វាមិ (ត្រីមហាបុរុឞោត្តមស្វាមិ) មានខ្ញុំបម្រើចំនួន៧នាក់ ស្រី៣នាក់ ប្រុស៤នាក់។

អត្ថបទនេះ ដកស្រង់និងសម្រួលពីអត្ថបទដែលធ្លាប់ចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយានាពេលកន្លងមក។ ខ្ញុំយកមកផ្សាយជាថ្មីនៅទីនេះ ដោយសង្ឃឹមថានឹងអាចរកឃើញទីតាំងពិតប្រាកដរបស់សិលាចារឹកនេះ។

### អត្ថបទជាអក្សរពុម្ពបុរាណ

១- អំនោយិអាចាយ៌្យធម៌្មបាលពួតវ្រះក

២- ម្រតាងអញ្ចត្រីមហាបុរុឞោត្តមស្វាមិក្ញុំ

៣- វ្រះកុអាសិហ្វលិ១ កុ{១} ាតិ១ កុ(ហ្វ)ញ៑១

៤- កុភាកិ១ វាបញ្ចមី១ វាធដ្ឋី១ វាបតុ

៥- ទ្ធគី១

### អត្ថបទជាអក្សរខ្មែរទំនើប

១- អំនោយិអាចាយ៌្យធម៌្មបាលពួតវ្រះក

២- ម្រតាងអញ្ចត្រីមហាបុរុឞោត្តមស្វាមិក្ញុំ

៣- វ្រះកុអាសិហ្វលិ១ កុ{១} ាតិ១ កុ(ហ្វ)ញ៑១

៤- កុភាកិ១ វាបញ្ចមី១ វាធដ្ឋី១ វាបតុ

៥- ទ្ធគី១

### អត្ថបទសម្រួលជាភាសាខ្មែរទំនើប

តង្វាយ(/អំណោយ)របស់អាចាយ៌្យធម្មបាល ចំពោះព្រះតម្កែងអញស្រីមហាបុរុសោត្តមស្វាមិ។ ខ្ញុំ(បម្រើ)ព្រះមាន កុអាសវល់១ កុ-ាត១ កុហ្វញ១ កុភាក១ វាបញ្ចមី១ វាធដ្ឋី១ វាបតុទ្ធសី១។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

## វាក្យសព្ទ

- ***កុ*** = *ពាក្យហៅស្ត្រីវណ្ណៈថ្នាក់ទាបឬជាអ្នកបម្រើនៅសម័យមុនអង្គរ*(Pou, 2004, p. 101)។ ឬមានន័យថា នារី ស្ត្រី ប្រពន្ធ(ជាពាក្យសម្រាប់ហៅនារីដែលជាអ្នកបម្រើនៅប្រាសាទឬវិហារនានា) (ឡុង, ២០០០, p. 120) សម្រាប់ប្រើតែនៅសម័យមុនអង្គរប៉ុណ្ណោះ។

- ***វា*** = *ពាក្យហៅមនុស្សប្រុសជាពិសេសមនុស្សថ្នាក់ទាបឬអ្នកបម្រើនៅសម័យមុនអង្គរ* (Pou, 2004, p. 427)។

- ***វ្រះកម្រតាង៑អញ*** = ជាពាក្យសម្រាប់ហៅអាទិទេពនិង៑ទេវៈ (ឡុង, ២០០០, p. 102,) ប្រើតែសម័យមុនអង្គរ។ ពាក្យនេះនៅសម័យអង្គរប្រើជា «វ្រះកម្រតេង៑អញ» ពាក្យបច្ចុប្បន្នក្លាយជា «ព្រះគម្តែង៑អញ»។


### ឯកសារយោង

ឡុង សៀម

(២០០០). *វចនានុក្រមខ្មែរបុរាណ (តាមសិលាចារឹកបុរេអង្គរ សតវត្សទី៦ -៨)*. ពេង៑ពុម្ពភ្នំពេញ

Pou, S.

(2004). *Dictionnaire Vieux Khmer—Français—Anglais* (L'harmattan).


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

# បញ្ជីរូបភាព



រូបសិលាចារឹកអ៊ុតផ្កាស្ទិករឹង



រូបគូសចម្លងតាមសិលាចារឹកដើម

អត្ថបទដោយៈ ហ៊ុន ឈុនតេង